ការផ្ទៀងផ្ទាត់មើលពតិមានសម្រាប់ម្ហូបអាហារមិនបាច់បង់ថ្លៃ និង បន្ធូរថ្លៃ

គ្រួសារទទួលប្រាក់ Food Stamp និងប្រាក់ជំនួយបណ្តោះអាសន្ន

សម្រាប់គ្រួសារខ្ចះខាត(TANF) : ប្រសិនបើលោកអ្នកទទួលប្រាក់ Food Stamp ឬ ប្រាក់ជំនួយបណ្តោះអាសន្ន សម្រាប់គ្រួសារខ្ចះខាត (TANF)សម្រាប់កូនលោកអ្នក លោកអ្នកគ្រាន់តែត្រូវផ្ញើរពតិមានដែលបង្ហាញឱយឃើញថា គ្រួសារលោកអ្នកបច្ចុប្នន្យនេះ ទទួលប្រាក់ជំនួយទាំងនោះតែប៉ុណ្ណោះ គឺគ្រប់គ្រាន់ហើយ ។ ពុំមានសេចក្តីត្រូវការពតិមានអ្វីថែមទៀតឡើយ ។ ពតិមាននោះគឺ:

- **លិខិតបញ្ជាក់អំពីប្រាក់ Food Stamp ឬ អំពីប្រាក់ TANF** បង្ហាញឱយឃើញនូវថ្ងៃខែ នៃរយះពេល បញ្ជាក់អះអាងពីរឿងនេះ ។
- **លិខិតពីការិយាល័យ Food Stamp ឬ សន្តិសុខសង្គម (Welfare)** ដែលនិយាយថា លោកអ្នកសព្វថ្ងៃនេះ កំពុងតែទទួលប្រាក់ Food Stamp ឬប្រាក់ TANF ។
- **បណ្ណ័សម្គាល់ការអនុញ្ញាត្តិឱយចូលរួម (ATP CARD)**

ប្រសិនបើកូនលោកអ្នក បានទទួលការអនុញ្ញត្តិ ឱយទទួលម្ហូបអាហារដោយមិនបាច់បង់ថ្លៃ ពីព្រោះលោកអ្នកកន្លងមក បានដាក់លេខ Food Stamp ឬ លេខ TANF នៅលើពាក្យរបស់កូន ក៏ប៉ុន្តែឥឡូវនេះ លែងទទួលបានប្រាក់ Food Stamp ឬប្រាក់ TANF តទៅទៀត ហើយលោកអ្នកចង់ទទួលបានចំណីអាហារ ដោយមិនចាំបាច់បង់ថ្លៃតទៅទៀតនោះ (១) បំពេញពាក្យសុំម្ហូបអាហារ ១ទៀត ដោយផ្ជាប់មកជាមួយនូវ ពតិមានប្រាក់ចំណូលរបស់មនុស្សរាល់គ្នា នៅក្នុងក្រុមគ្រួសារលោកអ្នក ។ (២) សរសេរឈ្មោះនិងលេខសន្តិសុខសង្គម (Social Security Number) របស់មនុស្សធំពេញវ័យម្នាក់ៗ នៅលើពាក្យ ឬ នៅលើក្រដាសមួយសន្លឹកផ្សេងទៀត រុចហើយ (៣) ផ្ញើរក្រដាសបើកប្រាក់ខែ ឬ ក្រដាសស្នាមផ្សេងទៀត ដែលបង្ហាញនូវប្រាក់ចំណូល របស់លោកអ្នក នៅបច្ចុប្នន្យនេះ ។